# ព្រឹត្តប័ត្រ ព័ត៌មាន លេខ ០៤

# គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយកម្រិតមូលដ្ឋានសហគមន៍ (CDRR)

ADB - Grant 9178 - CAM

## វគ្គបណ្តុះបណ្តាល ICT នៅកម្រិតមូលដ្ឋានសហគមន៍

*ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៨*



*សកម្មភាព **អ្នកស្រី ធួន ស្រីតូច** គឺជាសមាជិក គ.គ.ម.ឃ. នៅ ឃុំចង្ហា ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ចូលរួមវគ្គបណ្តុះបណ្តាល*



## វគ្គបណ្តុះបណ្តាល ICT ទៅឲ្យមន្ត្រីខេត្ត ស្រុក និងឃុំ/សង្កាត់ នៅខេត្តបន្ទាយមានជ័យលើកទី ០១

គ្រោះមហន្តរាយតែងតែកើតមានឡើងស្ទើរជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ ២០០៩ មក។ គ្រោះមហន្តរាយទាំងនោះរួមមាន ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ រន្ទះបាញ់ អគ្គីភ័យ ជំងឺឆ្លង និងគ្រោះថ្នាក់ចរាចរជាដើម។ ពេលមានគ្រោះមហន្តរាយ ម្តងៗធ្វើអោយខូចខាតផលដំណាំ ផ្ទះសំបែង ផ្លូវថ្នល់ សាលារៀន វត្តអារាម អាយុជីវិតមនុស្ស និងសត្វ ម្យ៉ាងទៀតធ្វើអោយពិបាកធ្វើដំណើរ ដាច់ស្បៀង កង្វក់បរិស្ថាន បាត់បង់ទឹកស្អាតដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អ្នករងគ្រោះជាពិសេសស្ត្រី កុមារ និងចាស់គ្មានទីពឹង ។

នៅក្នុងពេលកំពុងកើតមាន និងក្រោយពេលមានគ្រោះមហន្តរាយព័ត៌មាន និងរបាយការណ៍ទាក់ទងជាមួយគ្រោះមហន្តរាយសម្រាប់បញ្ជូនទៅថ្នាក់ជាតិ ឬទៅស្ថាប័ន និងក្រសួងមិនមានការចងក្រងបានត្រឹមត្រូវដោយសារកង្វះខាតសម្ភារ និងចំណេះដឹងក្នុងការគ្រប់គ្រង ការចែករំលែក និងការផ្សព្វផ្សាយព័ត៌មាន ជាពិសេសជាងនេះទៅទៀតគឺសមត្ថភាពនៅមានកំណត់ក្នុងការធ្វើទំនាក់ទំនង និងប្រើប្រាស់បច្ចេកវិទ្យាទំនើបៗដែលមានស្រាប់ ។

ដោយបានឃើញការពិតជាក់ស្តែងដូចច្នេះហើយ ទើបគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយកម្រិតមូលដ្ឋានសហគមន៍បានរៀបចំធ្វើលទ្ធកម្មសម្ភារ ICT (ព្យូទ័រយួរដៃ និងម៉ាស៊ីនព្រីនទ័រ) ផ្តល់ឲ្យដល់ស្រុកចំនួន១៨ និងឃុំ/សង្កាត់ចំនួន ៥៤ ដែលឋិតនៅក្នុងខេត្តទាំង ០៦ ដែលជាគោលដៅរបស់គម្រោង លើកលែងតែឃុំ/សង្កាត់ និងស្រុកណាដែលឋិតនៅក្នុងគោលដៅគម្រោង ADB ដូចគ្នា ។ ជាពិសេសគឺបានបង្កើតវគ្គបណ្តុះបណ្តាលការប្រើប្រាស់ផ្នែក រឹង និងទន់របស់ប្រព័ន្ធ ICT ជូនដល់ប្រធាន អនុប្រធាន និងសមាជិក លេខាធិការដ្ឋាន គ.គ.ម.ខ លេខាធិការដ្ឋាន គ.គ.ម.ស និងលេខាធិការដ្ឋាន គ.គ.ម.ឃ ដែលឋិតក្នុងគោលដៅខេត្តទាំង ០៦ ស្រុកទាំង ១៨ និងឃុំ/សង្កាត់ទាំង ៥៤ របស់គម្រោងផងដែរ។

ជាក់ស្តែងនៅថ្ងៃទី ២១-២៥ ខែឧសភា ឆ្នាំ២០១៨ មានវគ្គបណ្តុះបណ្តាល ICT លើកទី០១នៅសាកលវិទ្យាល័យបៀលប្រាយខេត្តបន្ទាយមានជ័យដែលមានអ្នកចូលរួមសរុបចំនួន ៣០នាក់ ស្ត្រីចំនួន ០៥នាក់ ដែលពួកគេសុទ្ធតែត្រូវបានជ្រើសរើសមកពី ០៣ស្រុក ០៩ឃុំ នៃខេត្តបន្ទាយមានជ័យ។ សូមបញ្ជាក់ថាក្រុមហ៊ុន SBK គឺជាក្រុមហ៊ុនមួយដែលត្រូវបានជ្រើសរើសដោយគម្រោងដើម្បីផ្តល់សេវាកម្មបណ្តុះបណ្តាល ICT ដល់ខេត្តទាំង ០៦ ស្រុកទាំង ១៨ និងឃុំ/សង្កាត់ទាំង ៥៤ របស់គម្រោង ។

អ្នកស្រី **ធួន ស្រីតូច** គឺជាសមាជិក គ.គ.ម.ឃ. នៅ ឃុំចង្ហា ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យជាអ្នកចូលរួមវគ្គបណ្តុះបណ្តាល ICT ម្នាក់ក្នុងចំណោម ៣០នាក់ បានមានប្រសាសន៍ថា "***កន្លងមកគាត់មិនបានទទួលការបណ្តុះបណ្តាល ICT ពីគម្រោងណាមួយទេ គឺគាត់រៀនចេះប្រើប្រាស់ប្រព័ន្ធនេះដោយខ្លួនឯង និងគ្មានមូលដ្ឋានត្រឹមត្រូវ ទើបតែថ្ងៃនេះទេគាត់បានយល់ច្រើនអំពីការប្រើប្រាស់ទាំងការអនុវត្តជាក់ស្តែង និងការប្រើប្រាស់នូវទ្រឹស្តី ហើយថែមទាំងមានមេរៀនជាភាសារខ្មែរអានទៀត គាត់សង្ឃឹមថាគាត់នឹងយកចំណេះដឹងទៅចែករំលែក និងបង្រៀនដល់ក្រុមការងារភូមិ និងឃុំ/សង្កាត់ដើម្បីបង្កើនសមត្ថភាពក្នុងការគ្រប់គ្រងព័ត៌មាន ការទំនាក់ទំនង និងការធ្វើរបាយការណ៍ដើម្បីជួយកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅក្នុង ភូមិ និងឃុំ/សង្កាត់គាត់***" ។ ក្នុងរយៈពេល ០៥ថ្ងៃនេះ អ្នកចូលរួមវគ្គបណ្តុះបណ្តាលទាំងអស់មានចិត្តរីករាយ និងស្វាគមន៍ ចំពោះគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយកម្រិតមូលដ្ឋានសហគមន៍ដែលបានបង្កើតវគ្គបណ្តុះបណ្តាល ICT ជូនដល់ខេត្ត ស្រុក និងឃុំ/សង្កាត់របស់គាត់ គាត់ប្តេជ្ញាចិត្តថានឹងយកចំណេះដឹងទាំងអស់នេះទៅចែករំលែក និងបង្ហាត់បង្រៀនដល់អ្នកពាក់ព័ន្ធដើម្បីឲ្យកាន់តែមានសមត្ថភាពក្នុងការជួយកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅក្នុង ភូមិ និងឃុំ/សង្កាត់គាត់ ។ ៚





